ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ៤៦២.២៤ ប្រក

# ប្រកាស
# ស្តីពី
# ការបង្កើតឯកសណ្ឋាន និង សញ្ញាសម្គាល់ សម្រាប់និស្សិតជ័យលាភីថ្នាក់បណ្ឌិត នៃបណ្ឌិត្យសភានគរបាលកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១០០៥/៤៤៤ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៥ ស្តីពីការកែសំរួលមាត្រា៨ មាត្រា១០ នៃព្រះរាជក្រឹត្យលេខនស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា

## សម្រេច

**ប្រការ១.—**

ត្រូវបានបង្កើតឯកសណ្ឋាន និង សញ្ញាសម្គាល់ សម្រាប់និស្សិតជ័យលាភីថ្នាក់បណ្ឌិតទាំងពីរភេទ នៃបណ្ឌិត្យសភានគរបាលកម្ពុជា ដើម្បីប្រើក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បណ្ឌិត ឬ ក្នុងពិធីផ្លូវការផ្សេងៗទៀត តាមការកំណត់របស់បណ្ឌិត្យសភានគរបាលកម្ពុជា។

**ប្រការ២.—**

គំរូឯកសណ្ឋាន និង គំរូសញ្ញាសម្គាល់ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣.—**

ឯកសណ្ឋាននិស្សិតជ័យលាភីថ្នាក់បណ្ឌិតទាំងពីរភេទ នៃបណ្ឌិត្យសភានគរបាលកម្ពុជា បែងចែកជាឯកសណ្ឋានបុរស និងឯកសណ្ឋាននារី ដែលមានលក្ខណៈ ដូចខាងក្រោម៖

១- ឯកសណ្ឋានបុរសរួមមាន៖

- មួកមានទម្រង់ជាមួកកាស្កេតធ្វើអំពីក្រណាត់ពណ៌ខៀវចាស់។ ជើងមួកមានកម្រងក្បាច់សន្លឹកភ្ញីទេសព័ទ្ធជុំវិញមួកដែលស្ថិតនៅចន្លោះវណ្ឌខាងលើបីខ្សែនិងខាងក្រោមបីខ្សែ មានពណ៌ទឹកមាស និងមានកម្ពស់សរុប ៣៩ ម.ម។ ក្បាំងមួកមានលម្អដោយវណ្ឌទឹកមាសបីខ្សែ។ នៅលើមុខមួកមានដាក់រូបព្រះសង្ការពណ៌ទឹកមាសទំហំកម្ពស់ ៧៨ ម.ម និងទទឹង ៧១ ម.ម។
- អាវដៃបំពង់វែង ពណ៌ខៀវចាស់ កកុជ ប៉ូលស្មា មានឡេវរូបព្រះសង្ការពណ៌ទឹកមាស ចំនួន៧គ្រាប់ និងមានហោប៉ៅចំនួន៤ (ហោប៉ៅ២ខាងលើ ជាហោប៉ៅប៉ះ និងហោប៉ៅ២ខាងក្រោម ជាហោប៉ៅកាត់) ដែលមានគម្របរាងស្លាបជ្រឹងនិងឡេវពណ៌ទឹកមាសសម្រាប់ហោប៉ៅនីមួយៗ។ ផ្នែកចុងដៃអាវលម្អដោយប៉ានក្បាច់ភ្ញីទេសចង្វាយពណ៌ទឹកមាស ដែលអមម្ខាងៗដោយឆ្នូតចំនួនបីជួរ មានទទឹងសរុប៨០ ម.ម។ ផ្នែកខាងក្រោយខ្នងអាវ មានថ្នេរចំកណ្ដាលបណ្ដោយខ្នង។
- ខោជើងវែងពណ៌ខៀវចាស់ ចង្កេះត គ្មានជីប មានហោប៉ៅចំនួន៤ (ហោប៉ៅចំហៀងមាត់បញ្ឆិតដេរបង្កប់ចំនួន២ និងហោប៉ៅខាងក្រោយចំនួន២ជាហោប៉ៅកាត់ មានឡេវ គ្មានគម្របនិងចោះរន្ធដាក់ឡេវចំនួនមួយគ្រាប់)។
- ស្បែកជើងឃ្លុបកខ្លី ពណ៌ខ្មៅ ចងខ្សែ និងមានស្រោមជើងពណ៌ខ្មៅ។

២- ឯកសណ្ឋាននារីរួមមាន ៖

- មួកមានទម្រង់ជាមួកសំបុកធ្វើអំពីក្រណាត់ពណ៌ខៀវចាស់។ ជើងមួកមានកម្រងក្បាច់សន្លឹកភ្ញីទេសផ្នែកខាងមុខដែលស្ថិតនៅចន្លោះវណ្ឌខាងលើបីខ្សែនិងខាងក្រោមបីខ្សែ មានពណ៌ទឹកមាស និងកម្ពស់សរុប ៣៩ ម.ម។ ក្បាំងមួកមានលម្អដោយវណ្ឌទឹកមាសបីខ្សែ។ នៅលើមុខមួកមានដាក់រូបព្រះសង្ការពណ៌ទឹកមាសទំហំកម្ពស់ ៥៣ ម.ម និងទទឹង ៥៤ ម.ម។
- អាវដៃបំពង់វែង ពណ៌ខៀវចាស់ កកុជ ប៉ូលស្មា មានឡេវរូបព្រះសង្ការពណ៌ទឹកមាស ចំនួន ៥គ្រាប់ និងមានហោប៉ៅចំនួន៤ (ហោប៉ៅ២ខាងលើ ជាហោប៉ៅប៉ះ និងហោប៉ៅ២ខាងក្រោម ជាហោប៉ៅកាត់) ដែលមានគម្របរាងស្លាបជ្រឹងនិងឡេវពណ៌ទឹកមាសសម្រាប់ហោប៉ៅនីមួយៗ។ ផ្នែកចុងដៃអាវលម្អដោយប៉ានក្បាច់ភ្ញីទេសចង្វាយពណ៌ទឹកមាស ដែលអមម្ខាងៗដោយឆ្នូតចំនួនបីជួរ មានទទឹងសរុប ៨០ ម.ម។ ផ្នែកខាងក្រោយខ្នងអាវ មានថ្នេរចំកណ្ដាលបណ្ដោយខ្នង។

- សំពត់ពណ៌ខៀវចាស់ ពុំមានលម្អដោយក្បាច់អ្វីទាំងអស់ គ្រាន់តែមានឆែកខាងក្រោយ ចំកណ្ដាល នៅផ្នែកខាងក្រោមនៃតួសំពត់ មានសម្រុងក្រោមជង្គង់ត្រឹមមួយភាគបីនៃស្មងជើង។
- ស្បែកជើងឃ្លុបកខ្លីពណ៌ខ្មៅ ចងខ្សែ មានបាតកែងរាបស្មើ និងមានស្រោមជើងពណ៌ខ្មៅ។

**ប្រការ៤.–**

សញ្ញាសម្គាល់នៃឯកសណ្ឋាននិស្សិតជ័យលាភីថ្នាក់បណ្ឌិតទាំងពីរភេទ មានលក្ខណៈរួម និងត្រូវកំណត់ដូចខាងក្រោម៖

១- សញ្ញាស្មាអាវ

សញ្ញាស្មាអាវ ធ្វើអំពីក្រណាត់ពណ៌ខៀវចាស់ មានរាងទ្រវែង រៀវកណ្ដាល ខាងចុងស្រួច។ ផ្នែកខាងលើមានឡេវព្រះសង្ការពណ៌ទឹកមាស ផ្នែកកណ្ដាល មានសញ្ញាពណ៌ទឹកមាសដែលជាផ្នែកកណ្ដាលនៃនិមិត្តសញ្ញារបស់បណ្ឌិត្យសភានគរបាលកម្ពុជា ទំហំកម្ពស់ ២៣ ម.ម និងទទឹង ២៣ ម.ម និងផ្នែកខាងក្រោមមានក្បាច់សន្លឹកភ្ញីទេសពណ៌ទឹកមាសទំហំកម្ពស់ ១៤ ម.ម និងទទឹង ៣២ ម.ម។ សញ្ញាស្មាអាវមានកម្រងក្បាច់សន្លឹកភ្ញីទេសជុំវិញ ដែលស្ថិតនៅចន្លោះវណ្ណខាងលើបីខ្សែ និងខាងក្រោមបីខ្សែទំហំទទឹង ៦ ម.ម។ សញ្ញានេះសម្រាប់ពាក់ជាប់លើប៉ូលស្មាទាំងពីរខាង។

ខ្នាតសញ្ញាស្មាអាវ៖

| | |
|---|---|
| - បណ្ដោយ | ១៣០ ម.ម |
| - ទទឹងខាងដើម | ៥៧ ម.ម |
| - ទទឹងកណ្ដាល | ៤៧ ម.ម |
| - ទទឹងខាងចុងកាច់ទៅចុងស្រួច | ៤៤ ម.ម |
| - ប្រវែងបញ្ចិតជ្រុងលើ | ៣០ ម.ម |
| - ឡេវរូបព្រះសង្ការអង្កត់ផ្ចិត | ១៥ ម.ម |

២- បន្ទោងនិមិត្តសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជា

បន្ទោងនិមិត្តសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជា មានរាងជាមេដាយដែលមានស្បែកបន្ទោងប្រវែង ១០០ ម.ម បាតស្រួចពណ៌ខៀវចាស់។ នៅលើស្បែកបន្ទោងមាននិមិត្តសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជា រាងមូលធ្វើពីលោហៈពណ៌ទឹកមាសនៅផ្នែកកណ្ដាល អង្កត់ផ្ចិតប្រវែង ៤៩ ម.ម សម្រាប់ពាក់បន្តោកជាប់ឡេវហោប៉ៅអាវលើផ្នែកខាងស្ដាំ។

៣- សញ្ញាកអាវ

សញ្ញាកអាវ មានលម្អដោយក្បាច់ភ្ញីទេស មានវណ្ណក្បាច់ធ្មេញក្របីព័ទ្ធជុំវិញពណ៌ទឹកមាស។ សញ្ញាក្បាច់ភ្ញីទេសនេះ មានរាងស្រដៀងប្រលេឡូក្រាម ទទឹង ៣៥ ម.ម និងបណ្ដោយ ៧៥ ម.ម។ សញ្ញានេះសម្រាប់ភ្ជាប់នៅលើចុងកអាវទាំងពីរខាង។

៤- ផ្លាកឈ្មោះ

ផ្លាកឈ្មោះ ធ្វើពីលោហៈ ផ្ទៃពណ៌ខៀវចាស់ មានស៊ុមពណ៌ទឹកមាសព័ទ្ធជុំវិញ បណ្ដោយ ៩០ ម.ម និងទទឹង ២០ ម.ម។ ឈ្មោះនិស្សិតជ័យលាភី សរសេរជាអក្សរខ្មែរក្នុងទម្រង់អក្សរមូល។ ផ្លាកឈ្មោះនេះសម្រាប់ពាក់នៅលើហោប៉ៅអាវលើផ្នែកខាងស្ដាំ។

៥- ផ្លាកសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជា

ផ្លាកសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជា ធ្វើអំពីលោហៈ មានរាងជារង្វង់មូល អង្កត់ផ្ចិតប្រវែង ៥០ ម.ម។ ផ្លាកសញ្ញានេះ សម្រាប់ពាក់នៅលើហោប៉ៅអាវលើផ្នែកខាងឆ្វេង។

**ប្រការ៥.—**

ឯកសណ្ឋាន និង សញ្ញាសម្គាល់ នៃឯកសណ្ឋាននិស្សិតជ័យលាភី មានអត្ថន័យដូចខាងក្រោម៖

១- ឯកសណ្ឋានត្រូវបានរចនាឡើងតាមលក្ខណៈខ្មែរ ដោយយកក្បាច់ភ្ញីទេសពណ៌ទឹកមាសមកប្រើសម្រាប់រចនាលម្អ និងមានលក្ខណៈស្រដៀងឯកសណ្ឋានកងកម្លាំងនគរបាលជាតិ។

២- មួកកាស្កេតសម្រាប់បុរសនិងមួកសំបុកសម្រាប់នារី ត្រូវបានរចនាឡើងស្របតាមទម្រង់នៃមួកកងកម្លាំងនគរបាលជាតិ ដែលផ្សារភ្ជាប់ទៅនឹងរចនាបថខ្មែរ។

៣- ព្រះសង្ហារពណ៌ទឹកមាសស្ថិតនៅលើមុខមួក មានន័យថាការតម្កល់ផលប្រយោជន៍ជាតិជាធំ ដោយគោរពតាមបាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ**។

៤- សញ្ញាស្មាអាវ ដែលមានសន្លឹកភ្ញីទេសពណ៌ទឹកមាស៣ទង តំណាងឱ្យថ្នាក់បណ្ឌិត។

៥- សញ្ញាពណ៌ទឹកមាសនៅកណ្តាលនៃសញ្ញាស្មាអាវ និងនិមិត្តសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជា តំណាងឱ្យស្ថាប័នបណ្តុះបណ្តាលកងកម្លាំងនគរបាលជាតិ។

៦- ពណ៌ខៀវចាស់ជាពណ៌តំណាងឱ្យសន្តិសុខ និងសុវត្ថិភាពសង្គមដែលជាភារកិច្ចស្នូលរបស់កងកម្លាំងនគរបាលជាតិ ក្នុងការបម្រើជាតិនិងប្រជាពលរដ្ឋ។

៧- ពណ៌ទឹកមាសជាពណ៌ដែលតំណាងឱ្យភាពថ្លៃថ្នូរនិងឧត្តុង្គឧត្តម។

៨- សន្លឹកក្បាច់ភ្ញីទេសតំណាងឱ្យវប្បធម៌ជាតិ ដែលមានលក្ខណៈសិល្បៈទន់ភ្លន់និងមានវឌ្ឍនភាពគ្មានដែនកំណត់។

**ប្រការ៦.—**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថលនិងផ្សព្វផ្សាយអប់រំ និងបណ្តាអង្គភាពពាក់ព័ន្ធ ត្រូវទទួលអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៩កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងអប់រំ យុវជន និងកីឡា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមអភិសន្តិបណ្ឌិតឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ៤៨០១.៤.....ប្រ.ក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៥
ការបង្កើតឯកសណ្ឋាន និង សញ្ញាសម្គាល់ សម្រាប់និស្សិតជ័យលាភី ថ្នាក់បណ្ឌិត
នៃបណ្ឌិត្យសភានគរបាលកម្ពុជា

## គំរូឯកសណ្ឋាន និង គំរូសញ្ញាសម្គាល់

### ១. សញ្ញាសម្គាល់

ព្រះសង្ហារ

សម្រាប់មួកកាស្កេត




សម្រាប់មួកសំបុក




បន្តោងនិមិត្តសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជា




និមិត្តសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជា




សញ្ញាស្មារអាវ
សម្រាប់ថ្នាក់បណ្ឌិត



## វណ្ឌជើងមួក




## សញ្ញាកអាវ




## ផ្លាកឈ្មោះ




## ប៉ានចុងដៃអាវ



## ២. មួក

### មួកកាស្កេតបុរស



### មួកសំបុកនារី



## ៣. ស្បែកជើង

### ស្បែកជើងបុរស



### ស្បែកជើងនារី



## ៤. ឯកសណ្ឋានបុរសសម្រាប់និស្សិតជ័យលាភី ថ្នាក់បណ្ឌិត



## ៥. ឯកសណ្ឋាននារីសម្រាប់និស្សិតជ័យលាភី ថ្នាក់បណ្ឌិត

